UNITED NATIONS
CAMBODIA

# សិទ្ធិមនុស្ស និងការឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ របស់អង្គការសហប្រជាជាតិនៅកម្ពុជា

## ឯកសារព័ត៌មានទី ២

## ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១

ខ្លឹមសារខាងក្រោមនេះ បង្ហាញពីព័ត៌មានបច្ចុប្បន្នភាពស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ចំពោះករណីផ្ទុះជំងឺនៅក្នុងសហគមន៍នាពេលបច្ចុប្បន្ន និងវិធានការឆ្លើយតបចំពោះជំងឺកូវីដ-១៩។

- ការចូលរួមសហការរបស់អង្គការសហប្រជាជាតិជាមួយនឹងរដ្ឋាភិបាលកម្ពុជា ធ្វើឡើងក្រោមក្របខ័ណ្ឌនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងកតិកាសញ្ញានានា ដែលរដ្ឋាភិបាលបានទទួលយកដោយស្ម័គ្រចិត្ត ក៏ដូចជាស្របតាមគោលដៅអភិវឌ្ឍន៍ដោយចីរភាព គោលការណ៍មិនទុកនរណាម្នាក់ចោល និងការអំពាវនាវរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិឱ្យមានការគោរពសិទ្ធិមនុស្ស។ ដូចគូសបញ្ជាក់នៅក្នុងឯកសារសង្ខេបគោលនយោបាយរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីជំងឺកូវីដ -១៩ និងបញ្ហាសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តកាលពីខែ មេសា ឆ្នាំ ២០២០ អង្គការសហប្រជាជាតិបានគូសបញ្ជាក់ជាមួយនឹងរដ្ឋាភិបាលថា បញ្ហាសិទ្ធិមនុស្សគឺជាកត្តាដ៏សំខាន់ នៅពេលរៀបចំការឆ្លើយតបចំពោះការរាតត្បាតជាសកល ទាំងសម្រាប់ស្ថានភាពបន្ទាន់ផ្នែកសុខភាពសាធារណៈផង ទាំងដើម្បីឆ្លើយតបចំពោះផលប៉ះពាល់ជារួមមកលើជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផង។

- អង្គការសហប្រជាជាតិទទួលស្គាល់ពីភាពចាំបាច់ក្នុងការអនុវត្តវិធានការនានា ដូចជា ការបិទខ្ទប់ទីក្រុងជាដើម ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។ វិធានការបិទខ្ទប់ទីក្រុងទាមទារឲ្យមានការថ្លឹងថ្លែង រវាងការសម្រេចគោលដៅសុខភាពសាធារណៈដែលជាគោលដៅដ៏សំខាន់ ជាមួយនឹងសិទ្ធិ ក៏ដូចជាតម្រូវការបន្ទាន់ដទៃទៀតរបស់បុគ្គល និងសហគមន៍ ជាពិសេសគ្រួសារមានចំណូលទាប។ អង្គការសហប្រជាជាតិបានជំរុញឲ្យរដ្ឋាភិបាលប្រកាន់យកអភិក្រម ដោយឈរលើគោលការណ៍សិទ្ធិមនុស្សនៅក្នុងការអនុវត្តវិធានការសុខភាពសាធារណៈរបស់ខ្លួន ជាមួយនឹងការផ្តល់អាទិភាពដល់ការអប់រំផ្សព្វផ្សាយដល់សហគមន៍ ដើម្បីធានាឲ្យមានការកំណត់ពីតម្រូវការចាំបាច់របស់ពួកគេ និងជួយឲ្យសហគមន៍អាចបំពេញតម្រូវការស្បៀង ឱសថ និងតម្រូវការចាំបាច់សំខាន់ៗដទៃទៀត ដូចជា តាមរយៈការផ្តល់ស្បៀងសង្គ្រោះដល់ប្រជាពលរដ្ឋ ដែលពុំមានលទ្ធភាពទិញស្បៀងអាហារទាំងនោះជាដើម។

- អង្គការសហប្រជាជាតិ បានជំរុញឲ្យអាជ្ញាធរផ្តល់អាទិភាពដល់ប្រជាពលរដ្ឋងាយរងគ្រោះជាងគេ នៅក្នុងការឆ្លើយតបរបស់ខ្លួន។ អង្គការសហប្រជាជាតិនឹងបន្តជំរុញឲ្យអាជ្ញាធរពិគ្រោះយោបល់ និងចូលរួមសហការជាមួយនឹងអ្នកពាក់ព័ន្ធ ក៏ដូចជា តំណាងរបស់ក្រុមប្រជាពលរដ្ឋពាក់ព័ន្ធជាមុន នៅក្នុងអំឡុងពេលនៃដំណើរការអនុវត្តវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩។ អង្គការសហប្រជាជាតិក៏បានចូលរួមសហការជាមួយនឹងរដ្ឋាភិបាល ដើម្បីធ្វើវិសោធនកម្មច្បាប់ និងគោលនយោបាយនានាដែលមិនស្របតាមបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ អង្គការសហប្រជាជាតិក៏បានបន្តចូលរួមសហការជាមួយរដ្ឋាភិបាល ក្នុងការជំរុញឲ្យមានការការពារបន្ថែមទៀតដល់ក្រុមដែលងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងជនមានពិការភាព ជាដើម។

- នៅក្នុងបរិបទនៃការឆ្លងរាលដាលជំងឺកូវីដ-១៩នៅពន្ធនាគារខេត្តព្រះសីហនុ អង្គការសហប្រជាជាតិ និងដៃគូមនុស្សធម៌ កំពុងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង ហើយនឹងផ្តល់ជំនួយមនុស្សធម៌បន្ទាន់ដល់អគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីកាត់បន្ថយហានិភ័យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងពន្ធនាគារនោះ។ ចាប់តាំងពីពេលដែលការរាតត្បាតជាសកលចាប់ផ្តើម អង្គការសហប្រជាជាតិ បានធ្វើការតស៊ូមតិជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងបានផ្តល់ការគាំទ្របច្ចេកទេស ដើម្បីឲ្យមានការប្រើប្រាស់មធ្យោបាយជាជម្រើសផ្សេងក្រៅតែពីការឃុំឃាំង ដើម្បីឆ្លើយតបទៅនឹងស្ថានភាពតូចចង្អៀតនៅតាមពន្ធនាគារ។ អង្គការសហប្រជាជាតិគូសបញ្ជាក់ពីការអំពាវនាវកន្លងមករបស់ខ្លួន ឲ្យមានការធ្វើការពិចារណាលើវិធានការនេះ ជាពិសេស សម្រាប់អនីតិជន ស្ត្រីមានផ្ទៃពោះ អ្នកជាប់ពន្ធនាគារដែលមានបញ្ហាសុខភាពប្រចាំកាយ អ្នកជាប់ឃុំមុនជំនុំជម្រះ និងអ្នកដែលជាប់ឃុំដោយសារការប្រព្រឹត្តបទល្មើសដែលមិនពាក់ព័ន្ធនឹងការប្រើប្រាស់អំពើហិង្សាជាដើម។

- ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បានបង្ហាញឲ្យឃើញពីភាពងាយរងគ្រោះនៃសេវាសង្គម និងសេវាថែទាំសុខភាពនៅកម្ពុជា ដែលអាចរុញច្រានប្រជាពលរដ្ឋឲ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ បច្ចុប្បន្ននេះអង្គការសហប្រជាជាតិកំពុងធ្វើការងារជាមួយរដ្ឋាភិបាល ដើម្បីពិភាក្សាពីរបៀបកែសម្រួលការប្រើប្រាស់ធនធានជាតិរបស់ខ្លួន ដើម្បីធានាឱ្យមានការផ្តល់អាទិភាពដល់ចំណាយរបស់វិស័យ សុខាភិបាល និងគាំពារសង្គម ដើម្បីឲ្យរដ្ឋាភិបាលអាចបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងបរិបទនៃការខិតខំសម្រេចឱ្យបានជាបណ្តើរៗនូវសិទ្ធិសេដ្ឋកិច្ចនិងសង្គមកិច្ច។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងនិងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។